

ប្រភពនៃសេចក្តីអំណរ



(12)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> មានមនុស្សជាច្រើនដែលនិយាយថា
> តើអ្នកណានឹងសម្តែងឲ្យយើងឃើញសេចក្តីល្អ?
> ឱព្រះយេហូវ៉ាអើយ
> សូមទ្រង់ប្រោសឲ្យរស្មីនៃព្រះភក្ត្រទ្រង់បានភ្លឺមកលើយើងខ្ញុំ
> រាល់គ្នា
> ទ្រង់បានប្រោសឲ្យចិត្តទូលបង្គំមានសេចក្តីអំណរលើសជា
> ងពួកទាំងនោះ ក្នុងកាលដែលស្រូវ
> និងទឹកទំពាំងបាយជូររបស់គេបានសម្បូរផង។
> [ទំនុកដំកើង ៤:៦-៧]

នេះគឺជាស្ថានភាពរបស់យើងពិតប្រាកដសព្វថ្ងៃនេះ។
មនុស្សជាច្រើនកំពុងស្រែ
តើអ្នកណាអាចសម្តែងឲ្យយើងឃើញពីសេចក្តីល្អបាន?
មានការស្រងាកចិត្តមួយប្រភេទ ដែលជាភាពទុទិដ្ឋិនិយមនៅក្នុងខ្យល់
ជាពិសេសនៅក្នុងវិស័យនយោបាយ
ការខ្វះទំនុកចិត្តលើភាពជាអ្នកដឹកនាំ
ជាការខកចិត្តយ៉ាងខ្លាំងដែលបានផ្តល់ឲ្យយើងក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗ
នេះ។ ប៉ុន្តែ នៅកណ្តាលនៃការទាំងអស់នេះមានចម្លើយមួយ។

តើអ្នកណាអាចសម្តែងឲ្យយើងឃើញពីសេចក្តីល្អបាន?

បន្ទាប់មកដាវីឌដែលជាអ្នកសរសេរទំនុកដំកើង បានបង្រៀនថា
«ឱព្រះយេហូវ៉ាអើយ
សូមទ្រង់ប្រោសឲ្យរស្មីនៃព្រះភក្ត្រទ្រង់បានភ្លឺមកលើយើងខ្ញុំរាល់គ្នា»។

សេចក្តីល្អពិតមានប្រភពតែមួយ។ វាមកពីព្រះអម្ចាស់
ហើយនៅពេលទ្រង់លើករស្មីនៃព្រះភក្ត្ររបស់ទ្រង់ចាំងមកលើយើង
រស្មីនោះបណ្តេញភាពងងឹត ភាពកង្វល់ ការព្រួយបារម្ភ
និងការភ័យខ្លាចរបស់យើងចេញ។
យើងត្រូវបានបំពេញដោយសេចក្តីអំណរ។ ដាវីឌបាននិយាយថា៖

> «ទ្រង់បានប្រោសឲ្យចិត្តទូលបង្គំមានសេចក្តីអំណរលើស
> ជាងពួកទាំងនោះ ក្នុងកាលដែលស្រូវ
> និងទឹកទំពាំងបាយជូររបស់គេបានសម្បូរផង»។

មានការសប្បាយ
និងការពេញចិត្តនិងសុភមង្គលដែលយើងទទួលបានពីភាពសម្បូរបែប
នៃសម្ភារៈ ប៉ុន្តែមានអ្វីមួយដែលខុសប្លែកគ្នា
ដែលមានតែចេញពីរស្មីនៃព្រះភក្ត្ររបស់ព្រះនៅលើជីវិតរបស់យើងប៉ុណ្ណោះ។

សេចក្តីអំណរពិតដែលហូរសពីអ្វីដែលយើងអាចទទួលបានពីភាពសម្បូរសប្បាយនៃសម្ភារៈ ឬសុវត្ថិភាព ឬការពេញចិត្តនៅក្រៅ។
ដូច្នេះសូមចាំថា
វានឹងជារស្មីនៃព្រះតក្កូរបស់ព្រះដែលនឹងធ្វើឲ្យជីវិតរបស់អ្នកមានន័យ និងមានសុវត្ថិភាព។

: WD-WFTW-012-KHM
: 24 Feb 2026
: derekprince.com/km/resources

